YUNNAN DAILY PRESS GROUP
云南日报报业集团
No.144

ប្រទេសចិន-ខេត្តយូនណាន

ទស្សនាប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 26 លេខ 7563 ថ្ងៃសុក្រ ទី16 ខែកុម្ភៈ ឆ្នាំ 2018

សិល្បករសិល្បការិនីចិន និងខ្មែររួមគ្នាសម្តែងកម្មវិធីសិល្បៈ អបអរខួបទី៦០នៃការបង្កើតទំនាក់ទំនងការទូតចិន និងកម្ពុជា



សិល្បករសម្តែងរបាំប្រពៃណី ជន ជាតិចិនមួយ (រូបថត ដោយ Ding Feng)

កាលពីរាត្រីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៨ រាត្រីសមោសរ ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីចិន និងខួបទី៦០ ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតចិន និងកម្ពុជា ដែលរៀបចំដោយស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជាបានប្រារព្ធនៅរោងល្ខោនចតុមុខក្នុង រាជធានីភ្នំពេញ។ សិល្បករសិល្បការិនីចិន និងខ្មែរបានរួមគ្នាសម្តែងកម្មវិធីសិល្បៈដ៏ទាក់ទាញក្នុងរាត្រីសមោសរនេះ។

សិល្បករ សិល្បការិនីចិន ដែលមកពីក្រុមសិល្បៈបូពាំនៃប្រទេសចិន និងសិល្បករ សិល្បការិនីខ្មែរបានរួមគ្នាសម្តែងកម្មវិធីសិល្បៈជូន ទស្សនិក-ជនជាតិ និងអន្តរជាតិជាង ៧០០នាក់ រួមមានតំណាងព្រះរាជវង្សានុវង្សខ្មែរ មន្ត្រីរាជការ និងមន្ត្រី ការទូតនៃបណ្តាប្រទេសនានាប្រចាំនៅប្រទេសកម្ពុជា។ ជាពិសេសបទចម្រៀង "អាឡោះអាល័យស្រុកចិន" ដែលច្រៀងជាភាសាចិន និងខ្មែរដោយអ្នកច្រៀងចម្រៀងចិន បានទទួលនូវការទះដៃកោតសរសើរពីទស្សនិជនគ្រប់រូប។

លោកស្បុង ពួ ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាបានមានប្រសាសន៍ថា នៅដើមឆ្នាំ២០១៨ ឯកឧត្តម លី ខឺឈាំង នាយករដ្ឋមន្ត្រីចិនបានអញ្ជើញមកបំពេញទស្សនកិច្ចដោយជោគជ័យនៅប្រទេសកម្ពុជា។ ដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីចិនបានបើកទំព័រនៃសកម្មភាពរួមគ្នាអបអរសាទរខួបទី៦០ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតចិន និងកម្ពុជា ហើយបានចាក់បញ្ចូលកម្លាំងចលករថ្មីសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរចិន និងកម្ពុជា។

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ភាគីទាំងពីរទំនាក់ទំនងរវាងប្រទេសចិន និងកម្ពុជានឹងអាចទទួលបានការរីកចម្រើនកាន់តែច្រើនថែមទៀត ព្រមទាំងនាំមកនូវផលប្រយោជន៍ជាក់ស្តែងកាន់តែច្រើនថែមទៀតដល់ប្រជាជននៃប្រទេសទាំងពីរ។

លោកស្រីភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជាមានប្រសាសន៍ថា មិត្តភាពកម្ពុជា និងចិនបាននាំមកនូវផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជននៃប្រទេសទាំងពីរ ហើយបានរួមចំណែកក្នុងការរក្សាសន្តិភាពនិងជំរុញការអភិវឌ្ឍន៍ក្នុងតំបន់ និងលើពិភពលោក ។ ពេលនេះ ក្រុមសិល្បៈបូពាំនៃប្រទេសចិនបានអញ្ជើញមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយបានរួមគ្នាសម្តែងកម្មវិធីសិល្បៈជាមួយសិល្បករសិល្បការិនីខ្មែរ។ នេះបានបង្ហាញឱ្យឃើញពីកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រលើវិស័យវប្បធម៌និងសិល្បៈរវាងប្រទេសទាំងពីរកម្ពុជានិង ចិន ។ លោកជំទាវបានគូសបញ្ជាក់ថាខ្ញុំពិតជាសប្បាយណាស់ដែលចូលរួមក្នុង សកម្មភាពអបអរសាទរបុណ្យចូលឆ្នាំថ្មី ចិនជាមួយអាណិកជនចិននៅប្រទេសកម្ពុជា៕

ដោយម៉ៅ ភីងហ្វី (ស៊ីនហួ ចិន)

ស្បៃវរហៅ "ស៊ុ ជីនភីង : អភិបាលកិច្ចប្រទេសចិន" [ភាគីទី២] បោះពុម្ពផ្សាយជាង១ពាលានក្បាលលើពិភពលោក

គិតមកដល់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០១៨ ស្បៃវរភៅ"ស៊ុ ជីនភីង: អភិបាលកិច្ចប្រទេសចិន"(ភាគីទី២) ជាភាសាចិន និងអង់គ្លេសដែលរៀបរៀង ដោយក្រសួងឃោសនាការមជ្ឈិមបក្សកុម្មុយ-នីស្តចិន (ការិយាល័យព័ត៌មាននៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន) ការិយាល័យសិក្សាស្រាវជ្រាវឯកសារមជ្ឈិមបក្សកុម្មុយនីស្តចិន និងអាជ្ញាធរភាសាបរទេសចិននិងបកប្រែដោយទីភ្នាក់ងារបោះពុម្ពផ្សាយស្បៃវរភៅជាភាសាបរទេសចិនបានត្រូវបោះពុម្ពផ្សាយជាង១៣លានក្បាលលើពិភពលោក ។ ស្បៃវរភៅ "ស៊ុ ជីនភីង : អភិបាលកិច្ចប្រទេសចិន" (ភាគីទី២) បានចងក្រងអត្ថបទចំនួន៨៨អត្ថបទរបស់ឯកឧត្តម ស៊ុ ជីនភីង ក្នុងចន្លោះពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ដែលក្នុងនោះរួមមានសុន្ទរកថា អនុសាសន៍សេចក្តីបង្គាប់បង្ហាញ និងសារលិខិតជូនពរជាដើម។ ស្បៃវរភៅនេះបែងចែកជាផ្នែកសំខាន់ចំនួន១៧ ដែលបានកត់ត្រានូវការអនុវត្តជាក់ស្តែងដ៏មហិមារបស់មជ្ឈិមបក្សកុម្មុយនីស្តចិន និងប្រជាជនគ្រប់ជនជាតិទូទាំងប្រទេសចិនក្នុងការជំរុញការអភិវឌ្ឍសង្គមនិយមដែលមានលក្ខណៈពិសេសចិន ហើយបានបង្ហាញដោយគ្រប់ជ្រុងជ្រោយនូវក្តីប្រាថ្នាចិន និងគម្រោងចិន ដែលបក្សកុម្មុយ-នីស្តចិនខិតខំ រួមវិភាគទានក្នុងការបង្កើតសហគមន៍ រួមវាសនាមនុស្សជាតិ ថែរក្សាសន្តិភាព និងជំរុញការអភិវឌ្ឍនៃមនុស្សជាតិទាំងមូល ។

សព្វថ្ងៃនេះស្បៃវរភៅ "ស៊ុ ជីនភីង: អភិបាលកិច្ចប្រទេសចិន" (ភាគីទី២) ជាភាសាចិនអក្សរពុម្ព (អក្សរបុរាណ) ព្រមទាំងភាសាបារាំង អេស្ប៉ាញ៉ូល អាល្លឺម៉ង់ ជប៉ុន អារ៉ាប់ និងព័រទុយហ្គាល់ កំពុងតែត្រូវបកប្រែនិងរៀបចំការបោះពុម្ពផ្សាយ៕

កីឡាករយូនណានចូលរួមការប្រកួតរត់ម៉ារ៉ាតុងពិភពលោក

ការប្រកួតរត់ម៉ារ៉ាតុងនៅទ្វីប អង់តាទិក គឺជាការប្រកួតមួយនៅក្នុងចំណោមការប្រកួតម៉ារ៉ាតុង ៧ ដែលរត់ឆ្លងកាត់៧ ទ្វីប (រូបថតផ្តល់ដោយ Jin Feibaos team)

ពេលថ្មីៗនេះការប្រកួតរត់ម៉ារ៉ាតុងពិភពលោកបានបើកការប្រកួតនៅទ្វីបអង់តាទិក ។ គួរបញ្ជាក់ថា មានជនជាតិចិនតែពីរនាក់ បានចូលរួមក្នុងការប្រកួតនេះក្នុងនោះមានលោក ជីន-ហ្វីប៉ាវ ដែលជាអ្នកផ្សងព្រេងម្នាក់មកពីខេត្តយូនណានប្រទេសចិន ។

ការប្រកួតរត់ម៉ារ៉ាតុងពិភព-លោកនេះជាការប្រកួតរត់ម៉ារ៉ាតុងអន្តរជាតិដ៏លំបាកមួយ ពីព្រោះកីឡាករកីឡាការិនីដែលចូលរួមក្នុងការប្រកួតនេះ ត្រូវតែចូលរួមការប្រកួតរត់ម៉ារ៉ាតុង៧ លើកនៅទ្វីបទាំង ៧ លើពិភពលោកក្នុងរយៈពេល៧ ថ្ងៃ ។ នេះមានន័យថា ពួកគេត្រូវតែធ្វើដំណើរយ៉ាងឆ្ងាយជាប់រហូតពីទ្វីបមួយទៅទ្វីបមួយទៀត ដើម្បីទៅចូលរួមការប្រកួតនៅទ្វីបទាំង៧ ក្នុងរយៈពេល ១៦៨ ម៉ោង ។ នៅទ្វីបនីមួយៗ ពួកគេត្រូវរត់ម៉ារ៉ាតុងចម្ងាយ៤២.១៩៥គីឡូម៉ែត្រសរុបរត់ចម្ងាយ២៩៥គីឡូម៉ែត្រនិងជិះយន្តហោះធ្វើដំណើរបាន៣៩.០០០គីឡូម៉ែត្រ ។

គួរបញ្ជាក់ថា មានជនជាតិចិនពានាក់បានចូលរួមក្នុងការប្រកួតនេះ គឺលោក ជីន ហ្វីប៉ាវដែលជាអ្នកផ្សងព្រេងមកពីខេត្តយូនណានលោក សហគ្រិន លី ជីនហុង និងលោក វិនិយោគិន លី ស្បៃវព្ជ ។ ក្នុងឱកាសនៃ ការប្រកួតនេះ លោកជីន ហ្វីប៉ាវមិនត្រឹមតែបានសាកល្បងរត់ម៉ារ៉ាតុងក្នុងបរិស្ថានដ៏លំបាក និងអាក្រក់ប៉ុណ្ណោះទេហើយបានខិតខំផ្សព្វផ្សាយអំពីការប្រកួតរត់ម៉ារ៉ាតុងតាមផ្លូវជនបទដ៏ទាក់ទាញ១០០ ខ្សែដែលនឹងរៀបចំនៅខេត្តយូនណាននាខែមេសាខាងមុខនេះ ដើម្បីអញ្ជើញឱ្យកីឡាករកីឡាការិនីបរទេសកាន់តែច្រើនមកចូលរួមក្នុងការប្រកួតរត់ម៉ារ៉ាតុងនេះនៅខេត្តយូនណាន ៕ **ដោយឡូវ យីង**

ខេត្តយូនណានចាប់អនុវត្តន៍គោលនយោបាយថ្មីអំពីការផ្តល់ទិដ្ឋាការដល់ជនបរទេសជាធនធានមនុស្សពីថ្ងៃទី១ខែមីនា

តាមសន្និសីទសារព័ត៌មានមួយដែលរៀបចំនៅថ្ងៃទី៦ ខែកុម្ភៈឆ្នាំ ២០១៨ បានឱ្យដឹងថាចាប់ពីថ្ងៃទី ១ ខែមីនាឆ្នាំ២០១៨ តទៅខេត្តយូនណាននឹងដាក់ចេញ និងអនុវត្តន៍គោលនយោ-បាយថ្មីអំពីការផ្តល់ទិដ្ឋាការដល់ជនបរទេសជាធនធានមនុស្ស ។ បន្ទាប់ពីអនុវត្តន៍គោលនយោបាយនេះជនបរ-ទេសដែលជាធនធានមនុស្សនឹងអាចទទួលបាននូវទិដ្ឋាការពិសេសដែលមានចិរវេលា ៥-១០ឆ្នាំសម្រាប់ចូលព្រំដែនចិនជាច្រើនលើក និងអាចស្នាក់នៅក្នុងប្រទេសចិន១៨០ ថ្ងៃរាល់ពេលចូលមកដល់ប្រទេសចិន ។ ចំណែកគ្រួសារនិងកូនដែលមិនពេញវ័យរបស់ជនបរទេសជាធនធានមនុស្សក៏អាចទទួលបាននូវទិដ្ឋាការពិសេស ដែលមានចិរវេលារយៈពេលយូរនិងអាចចូលព្រំដែនចិនជាច្រើនលើក ។

តាមប្រភពព័ត៌មានបានឱ្យដឹងថាទិដ្ឋាការពិសេសសម្រាប់ជនបរទេសជាធនធានមនុស្សនេះ(ទិដ្ឋាការ ប្រភេទ R) នឹងអាចទាក់ទាញធនធានមនុស្សអន្តរជាតិជាន់ខ្ពស់កាន់តែច្រើនមកធ្វើការនៅខេត្តយូនណាន។ ពួកគេនឹងរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការផ្ទាស់ទម្រង់អភិវឌ្ឍន៍សេដ្ឋកិច្ចនៃខេត្តយូនណាន ៕ **ដោយលី ហៃឈីវ**

រួមគ្នាអបអរបុណ្យចូលឆ្នាំថ្មីចិន

កាលពីថ្ងៃទី៧ ខែកុម្ភៈ ជនបរទេសជាង២០នាក់ បាននៅទេស្សនៈកិច្ច នៅភូមិមួយនៅជាយក្រុងប៉េកាំងដើម្បី ទទួលបទបុណ្យចូលឆ្នាំនៃនិទាឃរដូវ ។ នេះគឺជានិស្សិតមកពីប្រទេសបូស្វាណា សំដែងរបាំកាត់ក្រដាស (អ្នកថតរូបស៊ីនហួរ ដោយ Li Xin)

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីចិនទោះជានៅក្នុងឬក្រៅប្រទេសចិនក៏ដោយ លោកអ្នកសុទ្ធតែអាចទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីបរិយាកាសយ៉ាងសប្បាយរីករាយដែលនាំមកដោយបុណ្យចូលឆ្នាំថ្មីចិន ។ បច្ចុប្បន្នបុណ្យចូលឆ្នាំថ្មីចិនបានដើរចេញទៅក្រៅប្រទេសចិនដែលមិនគ្រាន់តែបាននាំយកបរិយាកាសសប្បាយរីករាយទៅដល់ប្រទេសផ្សេងៗប៉ុណ្ណោះទេ ថែមទាំងបានសម្តែងនូវសេចក្តីជូនពរដ៏ល្អបវរបស់ជនជាតិចិនជូនចំពោះប្រជាជន នៃបណ្តាប្រទេសនានាទៀតផង។ យើងអាចនិយាយថា បុណ្យចូលឆ្នាំថ្មីចិនបានក្លាយទៅជាខណៈពេលដ៏សំខាន់សម្រាប់ជំរុញការផ្លាស់ប្តូរផ្នែកវប្បធម៌និងអរិយធម៌រវាងប្រទេសចិន និងបណ្តាប្រទេសនានាលើពិភព-លោក ៕

(កាសែតប្រជាជនដេលី)

ចិននិងកម្ពុជាចុះកិច្ចព្រមព្រៀងស្តីពីគម្រោងគ្លីនិកចល័ត

ពេលថ្មីៗនេះកិច្ចព្រមព្រៀងស្តីពីគម្រោងគ្លីនិកចល័ត ដែលជាជំនួយប្រទេសចិនផ្តល់ដល់ប្រទេសកម្ពុជានោះបានត្រូវចុះហត្ថលេខាជាផ្លូវការនៅរាជធានីភ្នំពេញ។

លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលកម្ពុជានិង លោក លី អានទីប្រឹក្សាសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៃស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាបានអញ្ជើញចូលរួម និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ដោយតំណាងឱ្យភាគីទាំងពីរកម្ពុជានិងចិន ។

លោក ម៉ម ប៊ុនហេង មានប្រសាសន៍ថា ភាគីកម្ពុជាសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលចិនដែលបានផ្តល់ដល់ប្រទេសកម្ពុជានូវការគាំទ្រយ៉ាងពេញទំហឹង និងជំនួយឧបត្ថម្ភដ៏ច្រើនលើវិស័យសុខាភិបាល។ គ្លីនិកចល័តចំនួន៤០ ដែលជាជំនួយរបស់ប្រទេសចិននោះ ពិតជាមានសារសំខាន់ណាស់សម្រាប់ការអភិវឌ្ឍនៃប្រទេសកម្ពុជា ហើយក៏ជាសមិទ្ធផលដ៏សំខាន់មួយទៀតនៃការពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន និងការស្ថាបនា "ខ្សែក្រវាត់ និងផ្លូវ" ដែរ។ គម្រោងនេះនឹងអាចផ្តល់សេវាកម្មសុខាភិបាលដែលមានលក្ខណៈកាន់តែល្អប្រសើរដល់ប្រជាជននៃប្រទេសកម្ពុជា។

លោកលី អាន បានថ្លែងថាកម្ពុជាជាមិត្តល្អរបស់ចិន ។ គម្រោងគ្លីនិក ចល័តនេះនឹងអាចជួយដោះស្រាយបញ្ហា មើលជំងឺឱ្យប្រជាជនខ្មែរដែលរស់នៅក្នុងតំបន់ដាច់ស្រយាលនិងផ្តល់សេវាកម្មសុខា-ភិបាលដ៏ល្អប្រសើរដល់ប្រជាជនខ្មែរ ។

តាមប្រភពព័ត៌មានបានឱ្យដឹងថាគ្លីនិកចល័តដែលប្រទេសចិនផ្តល់ដល់ប្រទេសកម្ពុជានោះនឹងអាចផ្តល់សេវាកម្មសុខាភិបាលនិងព្យាបាលជំងឺធម្មតាផ្នែកជំងឺកុមារជំងឺឆ្លង ជំងឺស្ត្រីនិងសម្ភពជំងឺទន្តសាស្ត្រ ជំងឺត្រចៀកច្រមុះ និងបំពង់កជាដើម ៕

សេចក្តីជូនដំណឹង

សូមផ្តល់ព័ត៌មានជូនដល់មិត្តអ្នកអានថា ក្នុងបុណ្យចូលឆ្នាំថ្មីចិនខាងមុខទំព័រកាសែត"ខេត្តយូនណានប្រទេសចិន" នេះនឹងបញ្ឈប់ការបោះពុម្ពផ្សាយមួយលេខនៅថ្ងៃទី ២៣ ខែកុម្ភៈឆ្នាំ២០១៨ ។ ក្រោយពីបុណ្យចូលឆ្នាំថ្មីចិនយើងខ្ញុំនឹងរៀបចំការបោះពុម្ពផ្សាយឡើងវិញនៅថ្ងៃទី២ ខែមីនា ។ ឆ្លៀតយកឱកាសនេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះមិត្តអ្នកអានគ្រប់រូបដែលបានផ្តល់ការគាំទ្រនិងការយកចិត្តទុកដាក់ដល់កាសែតយើងខ្ញុំ ។ **សូមអរគុណ!**

ផ្នែករៀបរៀងនិងបោះពុម្ពផ្សាយ